


# Company Profile

# មាតិកា

**អំពីក្រុមហ៊ុន**

ប្រវត្តិក្រុមហ៊ុន

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សារពីអគ្គនាយិកា

ឯកសារចុះបញ្ជីកាសហគ្រាស

រចនាសម្ព័ន្ធសហគ្រាស

**ផលិតផលក្រុមហ៊ុន**

ផលិតផល

អត្ថប្រយោជន៍ផលិតផល

ដំណាក់កាលនៃការផលិត

ឧបករណ៍ប្រើប្រាស់ក្នុងការផលិត

ការចែកចាយផលិតផល

**សមិទ្ធផលជាតួលេខ**

**សកម្មភាពអាជីវកម្ម**

ការចូលរួមតាំងពិពណ៌ផលិតផលក្នុងស្រុក

ការទស្សនកិច្ចក្រៅប្រទេស

ដំណើរកំសាន្តប្រចាំឆ្នាំ

ការផ្តល់ឱ្យទៅកាន់សង្គម

**ហេតុផលដែលជ្រើសរើសសហការជាមួយសហគ្រាសយើងខ្ញុំ**

**ផែនការអនាគត**

ការអនុវត្តន៍ស្តង់ដាផលិតកម្ម និងផលិតដោយស្វ័យប្រវត្តិទាំងស្រុង

ការពង្រីកទំហំរោងចក្រ

ការទទួលអាជ្ញាបណ្ណនាំចេញក្រៅស្រុក

ការស្វែងរកដៃគូចែកចាយផ្តាច់មុខ

**អតិថិជនយើងខ្ញុំ**

**ការទំនាក់ទំនង**



# អំពីក្រុមហ៊ុន

## ប្រវត្តិក្រុមហ៊ុន

សូមស្វាគមន៍មកកាន់សហគ្រាសប្រេងកូឡាខ្មែររូបនាគព្រួសភ្លើងដែលជាសហគ្រាសមានកេរ្តិ៍ឈ្មោះក្នុងការផលិតប្រេងកូឡា និងប្រេងខ្យល់អស់រយៈកាលជាងមួយសតវត្សរ៍។

កាលដើមឡើយសហគ្រាសយើងខ្ញុំបង្កើតឡើងដំបូងត្រឹមតែជាសិប្បកម្មធ្វើដោយដៃតែប៉ុណ្ណោះក្រោមកិច្ចខិតខំប្រឹងប្រែងសហគ្រាសមួយនេះបានប្តូរទៅជាផលិតកម្មពាក់កណ្តាលស្វ័យប្រវត្តិក្រោមការដឹកនាំក្នុងឆ្នាំ2010 ដោយលោកស្រី អួន សុគន្ធា។

នៅក្នុងឆ្នាំ 2016 សហគ្រាសបានបន្តរីកចម្រើនទៅជាសហគ្រាសពន្ធមធ្យមសឱ្យឃើញពីការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍន៍ និងការបង្កើនភាពស្តង់ដា។

សហគ្រាសប្រេងកូឡាខ្មែររូបនាគព្រួសភ្លើងត្រូវបានបង្កើតឡើងដោយមានចក្ខុវិស័យក្នុងការរួមចំណែកគាំទ្រផលិតកម្មក្នុងស្រុក និងបណ្តុះស្មារតីជាតិនិយម សម្រាប់មនុស្សជំនាន់ក្រោយ។ បេសកកម្មរបស់យើងខ្ញុំគឺមិនមែនគ្រាន់តែដើម្បីផ្តល់ ផលិតផលដែលមានគុណភាពខ្ពស់ប៉ុណ្ណោះទេប៉ុន្តែជាការលើកទឹកចិត្តឱ្យអ្នកប្រើប្រាស់មានមោទនភាពក្នុងការគាំទ្រផលិតផលក្នុងស្រុកអាជីវកម្មក្នុងស្រុក និងជំរុញស្មារតីសហគមន៍ ។

ប្រេងកូឡា និងប្រេងខ្យល់រូបនាគព្រួសភ្លើង ជាផលិតផលតំណាងឱ្យអត្តសញ្ញាណខ្មែរដែលមានការលាយបញ្ចូលគ្នានៃពុទ្ធមន្ត108មុខដែលមានប្រភពមកពីដីមានជីជាតិ ក្នុងខេត្តបាត់ដំបង។ ផលិតផលមួយនេះមិនត្រឹមតែទទួលបានការគាំទ្រពីសំណាក់អតិថិជនជាច្រើនដោយសារប្រសិទ្ធភាពនៃការប្រើប្រាស់ក្នុងការថែទាំសុខភាពប្រចាំថ្ងៃ និងតម្លៃសមរម្យប៉ុណ្ណោះទេប៉ុន្តែផលិតផលនេះក៏ជាឫសគល់នៃការបង្ហាញប្រពៃណីខ្មែរផងដែរ។ សហគ្រាសយើងខ្ញុំមានទីស្នាក់ការកណ្តាលនៅទីក្រុងភ្នំពេញមានរោងចក្រ និងសាខាការិយាល័យតាមបណ្តាខេត្តនៅខេត្តបាត់ដំបង។





## ចក្ខុវិស័យ

ក្លាយជាសហគ្រាសផលិតប្រេងកូឡា ប្រេងខ្យល់ឈានមុខគេក្នុងប្រទេសកម្ពុជា និងនាំចេញលក់នៅលើទីផ្សារសកល ។

## បេសកកម្ម

បេសសកម្មរបស់យើងខ្ញុំគឺបង្កើនសមត្ថភាព នៅក្នុងការផលិត ប្រេងកូឡាប្រេងខ្យល់ ដើម្បីរក្សាកេរ្ត៍ដំណែលពុទ្ធមន្ត ១០៨មុខ។

បង្កើនការផ្សព្វផ្សាយដើម្បីក្លាយជាជម្រើសទីមួយសម្រាប់អតិថិជនក្នុងការប្រើប្រាស់ផលិតផលនេះ និងដើម្បីនាំចេញទៅកាន់ពិភពលោក ។

ប្ដេជ្ញាចិត្តបង្កើតផលិតផលថ្មីៗផ្ដល់នូវដំណោះស្រាយសុខុមាលភាពជូនអតិថិជនប្រកបដោយប្រសិទ្ធភាពក្នុងតម្លៃសមរម្យ។



# គុណតម្លៃ

## រក្សាប្រពៃណី និងកេរ្តិ៍ដំណែល

យើងខ្ញុំគោរពលើកតម្កើងប្រពៃណី និងបេតិកភណ្ឌដ៏យូរអង្វែងវប្បធម៌ខ្មែរ ធានាថារាល់ផលិតផលពីសហគ្រាសផលិតយើងខ្ញុំបានឆ្លុះបញ្ចាំងពីភាពពិត និងភាពសម្បូរបែបនៃប្រវត្តិសាស្ត្ររបស់យើង។

## ឧត្តមភាព និងគុណភាព

យើងខ្ញុំរក្សាជំហរ និងការប្តេជ្ញាក្នុងការចែកចាយផលិតផលប្រកបដោយគុណភាពតាមរយៈការបង្កើននូវស្តង់ដា និងធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ដើម្បីបំពេញការរំពឹងទុករបស់អតិថិជន និងស្តង់ដាផលិតកម្ម។

## សុខុមាលភាពអតិថិជន

សុខុមាលភាពរបស់អតិថិជនរបស់យើងខ្ញុំគឺនៅក្នុងបេះដូងនៃអ្វីៗគ្រប់យ៉ាងដែលយើងខ្ញុំធ្វើ។ យើងខ្ញុំប្តេជ្ញាផលិតក្នុងតម្លៃសមរម្យជាមួយនឹងផលិតផល ប្រកបដោយប្រសិទ្ធភាពដើម្បីបំពេញនូវតម្រូវការខុសៗគ្នារបស់អតិថិជន, លើកកម្ពស់សុខភាព និងភាពមាំទាំនៃប្រជាជនកម្ពុជា។

## ការបន្តរៀនសូត្រ

យើងខ្ញុំទទួលយកវប្បធម៌នៃការរៀនសូត្រ និងការអភិវឌ្ឍន៍ខ្លួនជាប្រចាំដោយជម្រុញការចង់ចេះចង់ដឹង។

## ការតស៊ូ

យើងខ្ញុំប្រឈមមុខនឹងបញ្ហាជាមួយការតស៊ូ និងការប្តេជ្ញាចិត្ត។

នៅគ្រប់ផ្នែកនៃការងាររបស់យើងខ្ញុំដោយបណ្តុះស្មារតីធន់ទ្រាំរៀនពីភាពបរាជ័យដើម្បីអភិវឌ្ឍន៍ខ្លួនកាន់តែខ្លាំង។

## សុចរិតភាព

យើងខ្ញុំធ្វើអាជីវកម្មជាមួយភាពស្មោះត្រង់តម្លាភាព និងក្រមសីលធម៌ដើម្បីធានានូវទំនុកចិត្តទំនួលខុសត្រូវក្នុងគ្រប់កិច្ចការដែលយើងខ្ញុំធ្វើ។









# សារពីអគ្គនាយិកា

ជូនចំពោះអតិថិជនជាទីគោរព!

ក្នុងនាមជាអគ្គនាយិកានៃសហគ្រាសប្រេងកូឡាខ្មែររូបនាគព្រួសភ្លើង យើងខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការផ្គត់ផ្គង់ផលិតផល ប្រកបដោយគុណភាព ប្រសិទ្ធភាព និងរក្សារូបមន្តប្រពៃណី ដែលបន្សល់ពីដូនតា។

ការជឿទុកចិត្ត និងការគាំទ្ររបស់អតិថិជនជំរុញឱ្យយើងខ្ញុំបន្តកែលម្អ កាន់តែប្រសើរ និងខិតខំដើម្បីបង្កើនឧត្តមភាព និងកិត្យានុភាពនៃផលិតផលក្នុងស្រុក។

ប្រសិនបើលោកអ្នកមានសំណួរ អំពីផលិតផលយើងខ្ញុំ ឬក៏ត្រូវការព័ត៌មានបន្ថែមអំពីភាពជាដៃគូផ្សេងៗ
សូមធ្វើការទំនាក់ទំនងមកយើងខ្ញុំ។

សូមអរគុណសម្រាប់ការផ្តល់ឱកាស។

**ដោយក្តីគោរព**



**លោកស្រី អូន សុគន្ធា**

**អគ្គនាយិកា**

# ឯកសារចុះបញ្ជីការសហគ្រាស

## ក្រុមហ៊ុនរបស់យើងខ្ញុំបានបង្កើតឡើងដោយស្របច្បាប់ និងត្រូវបានចុះបញ្ជីការក្រោម :

- ក្រសួងពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍












# រចនាសម្ព័ន្ធស្ថាប័ន



## ផលិតផលរបស់យើងខ្ញុំ៖

- ប្រេងកូឡាប្រទាលខ្មែរ បុរាណចំណុះ 50 ក្រាម
- ប្រេងកូឡាប្រទាលខ្មែរ បុរាណចំណុះ 15 ក្រាម
- ប្រេងកូឡានាគចំណុះ 50 ក្រាម
- ប្រេងកូឡានាគចំណុះ 15 ក្រាម
- ប្រេងខ្យល់ប្រទាលខ្មែរ បុរាណ
- ប្រេងខ្យល់ខ្មែរ រូបនាគព្រួសភ្លើង

## ផលិតផលរបស់យើងខ្ញុំអាចលាបជួយសម្រួលបានក្នុងករណីដែលលោកអ្នក៖

- ឈឺចុករោយតាមសន្លាក់ដៃជើង
- ឈឺក្បាលវិលមុខ
- ឈឺតាមសាច់ដុំ
- រលាកភ្លើង រលាកទឹកក្តៅ
- ហើម ចុក ឆ្អល់ រមួលពោះ
- ពុល ឡាន យន្តហោះ រលក
- ផ្តាសាយ ហៀរសំបោរ
- លាបរឹត ថ្លោះគ្រិច
- សត្វល្អិត ទិច រីខាំ
- ហើមជាំសាច់

**បញ្ជាក់:**

ប្រសិនបើអ្នកមានផ្ទៃពោះឬបំបៅកូនដោយទឹកដោះម្តាយឬប្រសិនបើអ្នកមានស្បែកងាយប្រតិកម្មសូមសួរគ្រូពេទ្យជំនាញមុននឹងប្រើ។

**រក្សាឱ្យឆ្ងាយពីកុមារ។**

**ការណែនាំ**

សម្រាប់មនុស្សពេញវ័យ និងកុមារអាយុលើសពី 12 ឆ្នាំ សូមលាបនៅកន្លែងដែលមានការឈឺចុកចាប់ម្តងហើយម្តងទៀតឱ្យបាន3-4ដងក្នុងមួយថ្ងៃ។

សម្រាប់កុមារអាយុចាប់ពី 12 ឆ្នាំឡើងទៅសូមពិគ្រោះជាមួយវេជ្ជបណ្ឌិតមុនពេលប្រើ។

**ព័ត៌មានផ្សេងទៀត**

សូមសាកល្បងលាបតិចៗសិនចំពោះបុគ្គលមួយចំនួនដែលមានប្រតិកម្មអាលែហ្ស៊ី ។



# ដំណាក់កាលនៃការផលិត



1. ដាំ និងគាស់បន្ទាល
2. ចម្រាញ់យកប្រេង (ប្រេងធ្វើជាធាតុផ្សំ)
3. ស្ល
4. ចាក់ទុកទៅជាគោក
5. ច្រករវេចខ្ចប់

# ឧបករណ៍ប្រើប្រាស់ក្នុងការផលិត



ម៉ាស៊ីនបោះពុម្ព
កាលបរិច្ឆេទផុតកំណត់



ម៉ាស៊ីន
កិបផលិតផល



ម៉ាស៊ីនស្លរ

# ការចែកចាយផលិតផល ផលិតផលរបស់ខ្ញុំចែកចាយទៅតាម :

- ឱសថស្ថាន
- ផ្សារទំនើប
- ដេប៉ូចាបហួយ
- ទីផ្សារក្រៅស្រុក

# អតិថិជនរបស់យើងខ្ញុំ

# សមិទ្ធផលជាតួលេខ

**100** អាយុកាលអាជីវកម្ម
ឆ្នាំ

**35** បុគ្គលិកជាង
នាក់

**លក់** ចេញទៅកាន់ទីផ្សារក្រៅប្រទេសដូច
ជាអាមេរិក វៀតណាម អូស្ត្រាលី ចិន
បារាំង និងកាណាដា

**ពង្រីក** រោងចក្រ



# សមិទ្ធផលនានា


荣誉证书
CERTIFICATE OF ACHIEVEMENT
Awarded to
DRAGON SPRAY FLAMES ENTERPRISE
In grateful acknowledgement of its contribution to
China-ASEAN Expo
And
Friendly cooperation between China and ASEAN countries
Over a span of 15 years
China-ASEAN Expo Secretariat


15年支持 15年辉煌
优秀参展商
BEST EXHIBITOR


ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING
MINISTRY OF LABOUR AND VOCATIONAL TRAINING
KHMER ENTERPRISE
លិខិតបញ្ជាក់
CERTIFICATE OF PARTICIPATION
Ms. AUN SOKUNTHEA
Founder of DRAGON SPAY FLAMES ENTERPRISE
Attended the training on "SMEs Development Program"
On 17 January-20 January 2023 at President Hotel
Battambang City, Battambang Province.


MEKONG INSTITUTE
KOICA
CERTIFICATE OF ACHIEVEMENT
MS. AUN SOKUNTHEA
With funding support from the Korea International Cooperation Agency (KOICA)

# ប័ណ្ណថ្លែងអំណរគុណ







# ប័ណ្ណសរសើរ









## ប័ណ្ណសមាជិកភាព


ប័ណ្ណសមាជិកភាព

Certification of Membership

លោកស្រី អូន សុគន្ធា

This certificate is given in recognition of the value contribution to

Mrs. Aun Sokunthea

Business owner of Dragon Balm

and has been registered as Member of Cambodian Women Entrepreneurs Association (CWEA)

on date: 02 Apr 2024 will be expired on date: 02 Apr 2025 in validity of 1 year of Membership registration Terms of condition.

## វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា


KINGDOM OF CAMBODIA

NATION - RELIGION - KING

ADB

Ministry of Commerce

Asian Development Bank

វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា

CERTIFICATE OF COMPLETION

This is to certify that ............OUN SOKUNTHEA.............................. has successfully completed the workshop on **The Dissemination of the Commercial Laws** (Law on Commercial Enterprises and Intellectual Property Law) from September 06-07, 2011 held at Battambang Provincial Department of Commerce.

# សកម្មភាពអាជីវកម្ម












- ដាក់ស្តង់នៅពិពណ៌ផលិតផលក្នុងស្រុក
- ទស្សនកិច្ចនៅប្រទេសចិនដើម្បីសិក្សាពីពិពណ៌ភូមិមួយផលិតផលមួយ
- ការផ្តល់ឱ្យទៅកាន់សង្គមតាមរយៈការបរិច្ចាគទៅកាន់កាកបាទក្រហម
- ដំណើរកំសាន្តប្រចាំឆ្នាំ

# ជូនផលិតផល ទៅថ្នាក់ដឹកនាំប្រទេស



# ហេតុផលដែលជ្រើសរើសសហការ ជាមួយសហគ្រាសយើងខ្ញុំ ?

- ផលិតផលផលិតពីពុទ្ធមន្ត១០៨មុខ រក្សារូបមន្តកេរ៌្តដូនតាខ្មែរ
- គាំទ្រសហគ្រិនស្ត្រី
- ជម្រុញប្រជាជនខ្មែរគាំទ្រផលិតផលក្នុងស្រុក
- ជួយដល់សេដ្ឋកិច្ចជាតិកាត់បន្ថយការនាំចូល
- ផលិតផលផ្តល់នូវដំណោះស្រាយសុខុមាលភាព ដ៏ប្រសើរ



# ផែនការអាជីវកម្មនាពេលអនាគត

- ពង្រឹងខ្សែសង្វាក់ផលិតកម្ម និងការវេចខ្ចប់អោយ ស្របស្តង់ដារអន្តរជាតិ និងផលិតដោយស្វ័យប្រវត្តិទាំងស្រុង
- ពង្រីករោងចក្រ
- ទទួលអាជ្ញាបណ្ណនាំចេញទៅក្រៅស្រុក
- ស្វែងរកដៃគូចែកចាយផ្តាច់មុខ



# សហគ្រាសផលិតប្រេងកូឡាខ្មែររូបនាគព្រួសភ្លើង គឺ ជាសមាជិកនៃ

*- CEO Master Club    - CWEA    - BNI Champion    - Khmer Enterprise*

# ការទំនាក់ទំនង

អាសយដ្ឋានទីស្នាក់ការកណ្តាលក្រុងភ្នំពេញ
ផ្ទះលេខ 60A, ផ្លូវ 371, សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

អាសយដ្ឋានសាខាការិយាល័យខេត្តបាត់ដំបង
ផ្ទះលេខ 73 ក្រុម25 ផ្លូវជាតិលេខ57 ភូមិអូរតាកាម ២ សង្កាត់ទួលតាឯក
ក្រុងបាត់ដំបង ខេត្តបាត់ដំបង

855 92 39 66 55 / 855 97 61 61 678
1774 719 3587

info@dragonbalm.com

www.dragonbalm.com

# សូមអរគុណ